# ចង់ស្គាល់ម្ល៉េះទេ...

ចង់ស្គាល់ម្ល៉េះទេរឿងស្នេហ៍តែម្ខាង
តើមានរូបរាងមានរសបែបណា
កើតមកជាមនុស្សមុខស្រស់ចិត្តភ្លា
មិនធ្លាប់ទុក្ខារឿងលួចស្នេហ៍គេ។
មានតែអ្នកមករាប់រកជាមិត្ត
យូរៗតាំងខិតចង់ចងចិត្តស្នេហ៍
បើខ្ញុំបណ្ដេញឱ្យចេញឈប់ក្បែរ
តាំងស្ដីត្អូញត្អែរថាដាច់មេត្តា។
បើខ្ញុំពេញចិត្តចងមិត្តរាប់អាន
តាំងប្រលំស្មានថាខ្ញុំស្នេហា
លោកនេះគ្មានទេឬមិត្តធម្មតា
ទាល់តែសង្សារទើបអាចជិតស្និទ្ធ ?
កុំចោទខ្ញុំខុសថាមនុស្សសាវ៉ា
ក៏កុំស្មានថាពិការដួងចិត្ត
ខ្ញុំគ្រាន់ពុំទាន់ជួបគូព្រេងព្រឹទ្ធិ
ពុំទាន់ព័ន្ធពិតស្នេហ៍ស្និទ្ធនរណា។
សេចក្ដីស្រលាញ់មានពេញហឫទ័យ
សង្ឃឹមមានថ្ងៃជួបជនថ្លៃថ្លា
ល្ហមល្ហាក់ឱ្យខ្ញុំជំពាក់ចិន្ដា
មានក្ដីស្នេហាចារជាប្រវត្តិ។
ចង់ស្គាល់ម្ល៉េះទេចិត្តស្នេហ៍គេមុន
តាមគយតាមគន់គេដោយប្រតិព័ទ្ធ
គេមិនដឹងអ្វីមិនស្ដីមិនឃាត់
ដូចផ្កាឈូករ័ត្នស្នេហ៍ព្រះសុរិយា៕

ប៊ុនចាន់ សុក្រសិរី

